# មណ្ឌលសិក្សាធិការយូនីហ្វៃដ៍អូកឡិនដ៍ បង្ហាញថា

# មគ្គុទ្ទេសក៍ស្តង់ដារមុខវិជ្ជាស្នូលរួមសម្រាប់មាតាបិតាក្នុងនាមជាដៃគូ ថ្នាក់មត្តេយ្យ

មណ្ឌលសិក្សាធិការយូនីហ្វៃដ៍អូកឡិនដ៍ ជឿទៅលើសំណុំមួយនៃជំនឿស្នូលអំពីគ្រួសារដែលយើងបម្រើជូនជារៀងរាល់ថ្ងៃ។

**ជំនឿគោល #1** មាតាបិតាទាំងអស់មានក្តីស្រមៃសម្រាប់កូនរបស់ខ្លួន និងចង់ឲ្យពួកគេល្អ

**ជំនឿគោល #2** ភាពជាដៃគូរជាមួយគ្រួសារគឺមានសារសំខាន់ចំពោះសមិទ្ធិផលនៃការសិក្សា

**ជំនឿគោល #3** មាតាបិតាទាំងអស់អាចគាំទ្រការសិក្សារបស់កូនរបស់ពួកគេបាន

**ជំនឿគោល #4** ការទទួលខុសត្រូវក្នុងការបង្កើតភាពជាដៃគូរវាងសាលា និងផ្ទះ ផ្អែកជាចំបងលើបុគ្គលិកសាលា ជាពិសេសថ្នាក់ដឹកនាំសាលា។

ពីព្រោះយើងប្រកាន់យកនូវជំនឿគោលលើការចូលរួមរបស់គ្រួសារ យើងបានបង្កើតសម្ភារ និងធនធានដើម្បីធានាថា គ្រួសារទាំងអស់យល់អំពី**ស្តង់ដារមុខវិជ្ជាស្នូល** និងអាចគាំទ្រការសិក្សានៅក្នុងផ្ទះ។ ធនធានទាំងនេះរួមមាន កញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោលទាំងអស់ (*Common Core Backpack*) ដែលទាំងនោះគឺជាសកម្មភាពដែលមាតាបិតាអាចប្រើនៅផ្ទះ ដើម្បីពង្រឹងស្តង់ដារនៃមុខវិជ្ជាគោលទាំងនោះ។

| តើអ្វីគឺស្តង់ដារមុខវិជ្ជាស្នូល? | ហេតុអ្វីត្រូវការមុខវិជ្ជាស្នូល |
|---|---|
| កាលពីមុន រដ្ឋនិមួយៗមានកម្រិតស្តង់ដារអប់រំរបស់ខ្លួន។ ចំណុចនេះបានបង្កឲ្យមានការ ភាន់ច្រលំ និងក្តីបារម្ភណ៍អំពីថាតើសិស្សរបស់យើងត្រៀមខ្លួនសម្រាប់ចូល មហាវិទ្យាល័យ និងអាជីពការងារនៅក្នុងពេលបញ្ចប់ការសិក្សាពីវិទ្យាល័យ ឬអត់។ រដ្ឋ កាលីហ្វ័រញ៉ា បានអនុម័តនូវស្តង់ដារមុខវិជ្ជាស្នូលនៅក្នុងឆ្នាំ 2010 ។<br><br>ស្តង់ដារមុខវិជ្ជាស្នូលរបស់រដ្ឋ (CCSS) គឺជាការរំពឹងទុកនៃការសិក្សាមួយនៅក្នុងសិល្បះ ភាសាអង់គ្លេស និងគណិតវិទ្យា ដែលបានបង្កើតឡើងដើម្បីត្រៀមសិស្សថ្នាក់ទី12 (K-12) ឲ្យចូលរៀនមហាវិទ្យាល័យ និងជោគជ័យអាជីពការងារ។ CCSS បង្ហាញឲ្យដឹងអំពីអ្វីដែល ត្រូវបានរំពឹងពីសិស្ស នៅតាមកម្រិតនិមួយៗ ដោយឲ្យសិស្ស មាតាបិតា គ្រូបង្រៀន និង អ្នកគ្រប់គ្រងសាលា ស្ថិតនៅក្នុងទីតាំងតែមួយដូចគ្នា ខណៈពេលកំពុងធ្វើការឆ្ពោះទៅរក គោលដៅរួមគ្នា។ | ស្តង់ដារមុខវិជ្ជាស្នូលរបស់រដ្ឋគឺមានសារសំខាន់ពីព្រោះមុខវិជ្ជាទាំងនេះនឹងជួយ កុមារទាំងអស់ មិនថាពួកគេជានរណានោះទេ សុទ្ធតែរៀនជំនាញដូចគ្នាសម្រាប់ត្រៀមចូល មហាវិទ្យាល័យ និងអាជីពការងារ។ ពួកគេបង្កើតការរំពឹងទុកច្បាស់លាស់មួយសម្រាប់ អ្វីដែលកូនរបស់អ្នកគួរដឹង និងអាចធ្វើ នៅក្នុងផ្នែកសំខាន់ផ្សេងៗ៖ អក្ខរកម្ម (**ការអាន សរសេរ និយាយ** និង**ស្តាប់**លើគ្រប់ផ្នែកនៃមុខវិជ្ជា) និង**គណិតវិទ្យា**។<br><br>ប្រសិនអ្នកដឹងការរំពឹងទុកទាំងនោះគឺជាអ្វី ក្រោយមកអ្នកអាចជួយកូនរបស់អ្នករៀបចំខ្លួន ពីព្រោះលោកអ្នកគឺជាគ្រូដំបូងរបស់កូនលោកអ្នក។<br><br>សិស្សរបស់យើងគឺជាអ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ អ្នកគ្រប់គ្រង និងអ្នករចនាប្លង់ នាពេលអនាគត។ ពួកគេគឺជាអ្នកដោះស្រាយបញ្ហា និងសហការ។ មុខវិជ្ជាស្នូលត្រៀម ធ្វើឲ្យពួកគេប្រកួតប្រជែងជាមួយ មិនមែនត្រឹមតែមិត្តភ័ក្រ្តជនជាតិអាមេរិកកាំងនៅក្នុងរដ្ឋផ្សេងទៀតប៉ុណ្ណោះទេ ប៉ុន្តែជាមួយសិស្សដែលមកពីបណ្តាប្រទេសនានាលើពិភពលោក។ |

## តើគ្រួសារអាចគាំទ្រជោគជ័យរបស់សាលាដោយរបៀបណា?

ភាពជាដៃគូរជាមួយគ្រួសារគឺមានសារសំខាន់សម្រាប់ជោគជ័យនៃការសិក្សា។ និយាយយ៉ាងសាមញ្ញ សាលាមិនអាចអប់រំសិស្សតែម្នាក់ឯងបានទេ។ តើគ្រួសារអាចធ្វើជាដៃគូរជាមួយ សាលាបានដោយរបៀបណា?

1. ដឹងពីអ្វីដែលកូនរបស់អ្នកគួររៀននៅថ្នាក់មត្តេយ្យ
2. សួរគ្រូថាតើកូនរបស់អ្នកមានទទួលជំនាញដែលបានបង្រៀនហើយឬនៅ
3. សួរថាតើលោកអ្នកអាចគាំទ្រការសិក្សានៅផ្ទះដោយរបៀបណា។ សួររកសកម្មភាពពីកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោលទាំងអស់ (Common Core Backpack) ដែលគឺជាសកម្មភាព ដែលមាតាបិតាប្រើនៅផ្ទះជាមួយកូន ដើម្បីទទួលបានចំណេះដឹងពីស្តង់ដារមុខវិជ្ជាស្នូលទាំងនោះ។
4. អាន អាន អាន។ សូមឲ្យកូនរបស់លោកអ្នកអានជារៀងរាល់ថ្ងៃ និងសួរសំណួរទៅពួកគេ។ ក្រោយមកទៀត ឲ្យពួកគេទៅអានអត្ថបទដើម្បីឆ្លើយសំណួរ

"តើអ្នកដឹងដោយរបៀបណា?

5. ត្រូវប្រាកដថា កូនរបស់លោកអ្នកគឺកំពុងអានសៀវភៅដែលមិនមែនជាប្រលោមលោកប្រឌិត ជាញឹកញាប់។

# ស្តង់ដារមុខវិជ្ជាស្នូលរួមសម្រាប់ថ្នាក់មត្តេយ្យ

នេះគឺជាបំណិន **<u>សិល្បៈភាសាអង់គ្លេស</u>** សំខាន់មួយចំនួនដែលត្រូវយកមកបង្រៀននៅក្នុងថ្នាក់មត្តេយ្យ។ សម្រាប់តារាងស្តង់ដារមុខវិជ្ជាស្នូលរដ្ឋកាលីហ្វ័រញ៉ា សូមចូលទៅ
គេហទំព័រក្រសួងអប់រំរដ្ឋកាលីហ្វ័រញ៉ា (http://www.cde.ca.gov/re/cc/).

មានសកម្មភាពពីកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោល សម្រាប់ស្តង់ដារមុខវិជ្ជាស្នូលនិមួយដែលមានរៀបរាប់ក្នុងបញ្ជីខាងក្រោម:

| ស្តង់ដារមុខវិជ្ជាស្នូលរួម | | ជាទូទៅ វាមានន័យថា កូនរបស់អ្នកអាច... |
|---|---|---|
| RL.K.1 | ដោយមានបម្រាប់ និងការគាំទ្រ សួរ និងឆ្លើយសំណួរអំពីសេចក្តីលម្អិតសំខាន់ៗនៅក្នុងអត្ថបទ។ | ប្រាប់អំពីនរណា អ្វី កន្លែងណា ពេលណា និងរបៀបណា ក្រោយពីបានស្តាប់រឿងចប់។ |
| RL.K.2 | ដោយមានបម្រាប់ និងការគាំទ្រ និទានរឿងស្រដៀងគ្នាឡើងវិញ រួមទាំងសេចក្តីលម្អិតផងដែរ។ | និទានរឿងណាមួយឡើងវិញ។ |
| RL.K.3 | ដោយមានបម្រាប់ និងការគាំទ្រ រកតួអង្គ ទស្សនីយភាព និងព្រឹត្តិការណ៍សំខាន់ៗនៅក្នុងរឿងណាមួយ។ | ប្រាប់អំពីតួអង្គ ទស្សនីយភាព និងអ្វីដែលបានកើតឡើងនៅក្នុងរឿងណាមួយ។ |
| RI.K.2 | ដោយមានបម្រាប់ និងការគាំទ្រ រកប្រធានបទសំខាន់ និងប្រាប់ឡើងវិញនូវសេចក្តីលម្អិតសំខាន់ៗរបស់អត្ថបទ។ | ប្រាប់អំពីប្រធានបទសំខាន់ និងសេចក្តីលម្អិតនៅក្នុងសៀវភៅដែលមិនមែនជារឿងប្រលោមលោកប្រឌិត។ |
| RL.K.5 | ស្គាល់ប្រភេទអត្ថបទសាមញ្ញៗ (ឧ. សៀវភៅរឿង កំណាព្យ)។ | ប្រាប់អំពីភាពខុសគ្នារវាងសៀវភៅរឿង និងកំណាព្យ។ |
| RL.K.6 | ដោយមានបម្រាប់ និងការគាំទ្រ ប្រាប់ឈ្មោះអ្នកនិពន្ធ និងជាងគំនូរនៅក្នុងរឿង និងកំណត់អំពីតួនាទីនៃបុគ្គលម្នាក់ៗនៅក្នុងការនិទានរឿងនោះ។ | ប្រាប់អំពីនរណាជាអ្នកនិពន្ធ និងនរណាជាជាងគំនូរ។ គេអាចប្រាប់អំពីការងាររបស់បុគ្គលទាំងនោះ។ |
| RI.K.5 | រកគម្របខាងមុខ គម្របខាងក្រោយ និងទំព័រចំណងជើងនៃសៀវភៅណាមួយ។ | ស្វែងរកគម្របខាងមុខ គម្របខាងក្រោយ និងទំព័រចំណងជើងនៅក្នុងសៀវភៅណាមួយ។ |
| RI.K.6 | ប្រាប់ឈ្មោះអ្នកនិពន្ធ និងជាងគំនូរនៅក្នុងអត្ថបទណាមួយ និងកំណត់អំពីតួនាទីនៃបុគ្គលម្នាក់ៗនៅក្នុងការបង្ហាញគំនិត ឬព័ត៌មាននៅក្នុងអត្ថបទ។ | ខ្ញុំអាចប្រាប់អំពីនរណាជាអ្នកនិពន្ធ និងនរណាជាជាងគំនូរ។ គេអាចប្រាប់អំពីការងាររបស់បុគ្គលទាំងនោះ។ |
| RL.K.7 | ដោយមានបម្រាប់ និងការគាំទ្រ ពណ៌នាអំពីទំនាក់ទំនងរវាងរូបគំនូរ និងរឿងដែលមានរូបគំនូរទាំងនោះ (ឧ. តើរូបគំនូរនេះពណ៌នាអំពីកាលណាមួយនៅក្នុងរឿង)។ | ប្រើរូបគំនូរដើម្បីជួយដល់ការនិទានរឿង។ |
| RF.K.1 | បង្ហាញឲ្យឃើញនូវការយល់ដឹងអំពីការរៀបចំ និងលក្ខណៈមូលដ្ឋានគ្រឹះនៃឯកសារបោះពុម្ព។<br>a. អានពាក្យពីឆ្វេងទៅស្តាំ ពីលើចុះក្រោម និងមួយទំព័រម្តងៗ<br>b. ស្គាល់ថា ពាក្យនិយាយមានតំណាងនៅក្នុងភាសាសរសេរតាមរយៈលំដាប់លំដោយនៃអក្សរជាក់លាក់។<br>c. យល់ថា ពាក្យខណ្ឌចែកពីគ្នានៅក្នុងឯកសារបោះពុម្ព។<br>d. ស្គាល់ និងប្រាប់ឈ្មោះអក្ខរក្រមជាអក្សរធំ និងអក្សរតូចទាំងអស់។ | ប្រើលក្ខណៈមូលដ្ឋានគ្រឹះនៃអត្ថបទដើម្បីជួយដល់ពួកគេក្នុងការអាន។ (អានពីឆ្វេងទៅស្តាំ អានពីលើចុះក្រោម ដកឃ្លានៅចន្លោះពាក្យនីមួយៗ)<br><br>ស្គាល់ និងប្រាប់ឈ្មោះអក្សរធំ និងអក្សរតូចទាំងអស់។ |

# ស្តង់ដារមុខវិជ្ជាស្នូលរួមសម្រាប់ថ្នាក់មត្តេយ្យ

ទាំងនេះគឺជាបំណិន **<u>គណិតវិទ្យា</u>** សំខាន់ៗដែលកំពុងត្រូវបានបង្រៀននៅថ្នាក់មត្តេយ្យ។ សម្រាប់បញ្ជីទាំងស្រុងស្តីពីស្តង់ដារមុខវិជ្ជាស្នូលរួមរបស់រដ្ឋកាលីហ្វ័រញ៉ា សូមមើល
វិបសាយរបស់ក្រសួងអប់រំរដ្ឋកាលីហ្វ័រញ៉ា (http://www.cde.ca.gov/re/cc/)។

មានសកម្មភាពកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោលសម្រាប់ស្តង់ដារមុខវិជ្ជាស្នូលរួមនីមួយៗ ដូចមានរាយឈ្មោះនៅខាងក្រោម។

| ស្តង់ដារមុខវិជ្ជាស្នូលរួម | | ជាទូទៅ វាមានន័យថា កូនរបស់អ្នកអាច... |
|---|---|---|
| K.CC.1 | រាប់ដល់ 100 ម្តងមួយ និងម្តងដប់។ | រាប់ដល់ 100 ម្តងមួយ និងម្តងដប់។ |
| K.CC.2 | រាប់ទៅមុខ ដោយចាប់ផ្តើមពីលេខដែលបានផ្តល់ឲ្យនៅក្នុងលំដាប់លំដោយដែលបានដឹង (ជំនួសឲ្យការត្រូវតែចាប់ផ្តើមពី 1)។ | រាប់ទៅមុខ ដោយចាប់ផ្តើមពីលេខដែលបានផ្តល់ឲ្យ។ |
| K.CC.3 | សរសេរលេខពី 0 ដល់ 20។ តំណាងលេខណាមួយនៃវត្ថុទាំងឡាយជាមួយនឹងតួលេខសំណេរពី 0-20 (ជាមួយនឹងលេខ 0 ដែលតំណាងឲ្យការមិនរាប់វត្ថុណាមួយ)។ | សរសេរលេខចាប់ពី 0 ដល់ 20។ សរសេរលេខណាមួយសម្រាប់ក្រុមវត្ថុដែលមានចំនួនចាប់ពី 0 ដល់ 20។ |
| K.CC.4 | យល់អំពីទំនាក់ទំនងរវាងចំនួន និងបរិមាណ ភ្ជាប់ចំនួនរាប់ទៅនឹងចំនួន<br>រៀប។<br>a. នៅពេលរាប់វត្ថុ ប្រាប់ឈ្មោះចំនួនតាមលំដាប់លំដោយស្តង់ដារ ដោយដាក់វត្ថុនីមួយៗទៅតាមគូដែលមានឈ្មោះចំនួនមួយ និងតែមួយ និងឈ្មោះចំនួននីមួយៗដែលមានវត្ថុមួយ និងតែមួយ។<br>b. យល់ថា ឈ្មោះចំនួនចុងក្រោយដែលបាននិយាយប្រាប់អំពីចំនួនវត្ថុដែលបានរាប់។ ចំនួននៃវត្ថុគឺដូចគ្នាទោះបីជាវាត្រូវបានរៀបចំយ៉ាងណា ឬរាប់តាមលំដាប់លំដោយណាក៏ដោយ។<br>c. យល់ថា ឈ្មោះចំនួនបន្តបន្ទាប់នីមួយៗគឺសំដៅទៅលើបរិមាណណាមួយដែលធំជាង។ | រៀបលេខតាមលំដាប់លំដោយ។ |
| K.CC.5 | រាប់ចំពោះសំណួរឲ្យឆ្លើយ "ប៉ុន្មាន?" អំពីវត្ថុដែលស្មើនឹង 20 ដែលត្រូវបានរៀបចំនៅក្នុងជួរមួយ លំដាប់ជួររាងចតុកោណ ឬរាងជារង្វង់ ឬស្មើនឹងវត្ថុ 10 ដែលមានរាងជាការពង្រាយត្រង់នេះបន្តិចត្រង់នោះបន្តិចផ្តល់ចំនួនណាមួយចាប់ពី 1–20 រាប់វត្ថុដែលច្រើននោះ។ | រាប់ចំនួនវត្ថុចន្លោះពី 1 ទៅ 20។ |
| K.CC.6 | កំណត់ថាចំនួនវត្ថុនៅក្នុងក្រុមមួយគឺច្រើនជាង តិចជាង ឬស្មើនឹងចំនួនវត្ថុនៅក្នុងក្រុមមួយផ្សេងទៀត ឧ. ដោយប្រើយុទ្ធសាស្ត្រផ្គូផ្គង និងរាប់។ 1 | ប្រាប់ថាតើ វត្ថុនៅក្នុងក្រុមមួយគឺច្រើនជាង តិចជាង ឬស្មើនឹងវត្ថុនៅក្នុងក្រុមមួយផ្សេងទៀតឬយ៉ាងណា។ |
| K.OA.1 | តំណាងឲ្យវិធីបូក និងវិធីដកដោយវត្ថុ ម្រាមដៃ រូបភាពក្នុងចិត្ត គំនូរ 2 សំឡេង (ឧ. ការទះដៃ) សម្តែងអំពីស្ថានភាព ការពន្យល់ដោយផ្ទាល់មាត់ សំនួនវោហារស័ព្ទ ឬសមីការ។ | ប្រើវត្ថុ ម្រាមដៃ និងរូបភាពដើម្បីជួយបង្ហាញវិធីបូក និងវិធីដក។ |
| K.NBT.1 | ផ្គុំ និងបំបែកចំនួនចាប់ពី ១១ ដល់ ១៩ ទៅជាមួយដប់ដង និងមួយមួយដងខ្លះ ឧ. ដោយប្រើវត្ថុ និងគំនូរ និងកត់ត្រាការផ្គុំ និងការបំបែកនីមួយៗដោយគំនូរ និងសមីការមួយ (ឧ. 18 = 10 + 8) យល់ថាចំនួនទាំងនេះគឺផ្គុំមកពីមួយដប់ដង មួយដង ពីរដង បីដង បួន | ប្រើវត្ថុ គំនូរ ឬសមីការដើម្បីបង្ហាញចំនួនមួយដប់ដង និងមួយមួយដង។ |

| | | |
|---|---|---|
| | ដង ប្រាំដង ប្រាំមួយដង ប្រាំពីរដង ប្រាំបីដង ឬប្រាំបួនដង។ | |
| K.MD.2 | ប្រៀបធៀបដោយផ្ទាល់នូវវត្ថុពីរជាមួយនឹងលក្ខណៈរង្វាស់ដែលនិយមប្រើប្រាស់ ដើម្បីឲ្យដឹងថាតើវត្ថុណាមួយមានលក្ខណៈ "ច្រើនជាង"/"តិចជាង" និងពណ៌នាអំពីភាពខុសប្លែកគ្នា។ ឧទាហរណ៍ ប្រៀបធៀបដោយផ្ទាល់នូវកម្ពស់នៃកុមារពីរនាក់ និងពណ៌នាថាតើកុមារណាម្នាក់ខ្ពស់ជាង/ទាបជាង។ | ប្រៀបធៀបថាតើវត្ថុពីរស្រដៀងគ្នា ឬខុសប្លែកគ្នាដូចម្តេចខ្លះ។ (ច្រើនជាង តិចជាង ខ្ពស់ជាង ទាបជាង) |
| K.MD.3 | ចាត់ថ្នាក់វត្ថុទៅជាប្រភេទដែលបានផ្តល់ឲ្យ រាប់ចំនួនវត្ថុនៅក្នុងប្រភេទនីមួយៗ និងតម្រៀបប្រភេទដោយរាប់។ 3 | រៀបវត្ថុចូលទៅតាមប្រភេទ។ |

*ស្តង់ដារដែលមានភាពងាយស្រួលសម្រាប់មាតាបិតា ដែលដកស្រង់ពីលោក Jill និង Cathey Henry។ "I Can Standards." www.thecurricculumcorner.com. ថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2012*